CDRI Cambodia Development Resource Institute

ANZ Royal

# សង្ខេបចក្ខុវិស័យប្រទេសកម្ពុជា

## ការឈានឡើងក្នុងខ្សែសង្វាក់បង្កើតតម្លៃសម្រាប់ ឧស្សាហូបនីយកម្ម កំណើន និងការអភិវឌ្ឍ ក្នុងសម័យឌីជីតាល់

គោលនយោបាយអភិវឌ្ឍន៍ឧស្សាហកម្មឆ្នាំ២០១៥-២៥ បានកំណត់ចក្ខុវិស័យសម្រាប់ប្រទេសកម្ពុជា ដើម្បីប្រែក្លាយ និងធ្វើទំនើបកម្មរចនាសម្ព័ន្ធឧស្សាហកម្មរបស់ខ្លួន ចេញពី ឧស្សាហកម្មប្រើពលកម្មច្រើន ទៅជា ឧស្សាហកម្មជំរុញឡើងដោយជំនាញ និងបច្ចេកវិទ្យា នៅត្រឹមឆ្នាំ២០២៥។ ការចូលរួម និងឈានឡើងក្នុងខ្សែសង្វាក់បង្កើតតម្លៃ គឺសំខាន់បំផុតដើម្បីសម្រេចគោលដៅប្រកបដោយមហិច្ឆតានេះ។

*សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន*
*នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា*

### តើខ្សែសង្វាក់បង្កើតតម្លៃសាកលជាអ្វី?

ខ្សែសង្វាក់បង្កើតតម្លៃសកល (GVC) សំដៅដល់ជំហានផ្សេងៗមួយខ្សែដែលក្នុងនោះ ធាតុចូលអន្តរការីមួយចំនួន ដូចជា បំណែក និងគ្រឿងផ្សំផ្សេងៗ គឺមានប្រទេសមួយផលិតវាឡើង រួចហើយនាំចេញទៅប្រទេសដទៃដើម្បី កែច្នៃបន្ថែម និង/ឬ ផ្គុំដំឡើង ជាផលិតផលសម្រេច។ តួយ៉ាង ការផលិត ទូរស័ព្ទ Apple iPhone4 រួមមានកិច្ចការស្មុគស្មាញមួយខ្សែអនុវត្តឡើងដោយប្រទេសផ្សេងៗ៖ ការរចនារៀបចំ(design) ធ្វើឡើងនៅសហរដ្ឋអាមេរិក កម្មវិធីបញ្ជា (software)នៅឥណ្ឌា ឈីប(silicon chip)នៅសិង្ហបុរី ហើយលោហៈដីកយកនៅបូលីវី។ ប្រទេសចម្បងៗឯទៀតដែលផ្គត់ផ្គង់បំណែក និងគ្រឿងផ្សំ iPhone រួមមាន កូរ៉េខាងត្បូង ជប៉ុន អាឡឺម៉ង់ និង បារាំង។ បំណែក/គ្រឿងផ្សំ ទាំងអស់ គេដឹកទៅចិនដើម្បីផ្គុំដំឡើងជាផលិតផលសម្រេច រួចហើយនាំចេញទៅសហរដ្ឋអាមេរិកដើម្បីធ្វើការផ្សាយលក់ និងចែកចាយជាសាកល។ GVCs ជារឿយៗមានក្រុមហ៊ុនពហុជាតិ (MNCs) ធ្វើការសម្របសម្រួលតាមរយៈបណ្ដាញសាខា ដៃគូជាប់កិច្ចសន្យា និងអ្នកផ្គត់ផ្គង់ប្រយោលជាច្រើន។ ក្នុងពិភពលោកដែលកំពុងមានការថយចុះរបាំងពាណិជ្ជកម្ម និងតម្លៃដឹកជញ្ជូន និងមាននវានុវត្តន៍ផ្នែកឌីជីតាល់កាន់តែលឿនឡើងនោះ ការបំបែកផលិតកម្មនៅក្នុង GVCs ផ្ដល់ឱកាសឲ្យក្រុមហ៊ុនពហុជាតិ រកបានតម្លៃទាប ធាតុចូលមានគុណភាពកាន់តែល្អ ហើយទាំងអស់នេះចូលរួមបង្កើនប្រសិទ្ធភាព និងភាពប្រកួតប្រជែង។

### ហេតុអ្វីបានជាការឈានឡើងក្នុងខ្សែសង្វាក់បង្កើតតម្លៃសំខាន់ជាខ្លាំងសម្រាប់កម្ពុជា?

មានហេតុផលពីរយ៉ាងដែល កម្ពុជាត្រូវខំឈានឡើងក្នុងខ្សែសង្វាក់បង្កើតតម្លៃ។ ទី១ GVCs បានក្លាយជា គំរូជាក់ស្ដែងមួយនៃការអភិវឌ្ឍសម្រួលដោយ តម្លៃដឹកជញ្ជូនធ្លាក់ចុះ របាំងពាណិជ្ជកម្មថយចុះ និងប្រព័ន្ធឌីជីតាល់កាន់តែមានយកមកប្រើច្រើនឡើង។ ប្រទេសភាគច្រើនប្រកួតប្រជែងគ្នាកាន់តែខ្លាំង ដើម្បីដាក់បញ្ចូលសហគ្រាសរបស់ខ្លួន និងជួយពួកគេឲ្យឈានឡើងក្នុងខ្សែសង្វាក់បង្កើតតម្លៃ ព្រោះ GVCs ជាកត្តាសំខាន់បង្កើនផលិតភាព បង្កើនការនាំចេញ និងបង្កើតការងារ។ ការចូលរួម និង ការឈានឡើងក្នុងខ្សែសង្វាក់បង្កើតតម្លៃ ក៏អាចជួយរួមចំណែកដល់ការអភិវឌ្ឍវិស័យឯកជន តាមរយៈ កំណើនវិនិយោគផ្ទាល់ពីបរទេស ការមានបណ្ដាញថ្មីៗនិងទីផ្សារសាកល ការផ្ទេរបច្ចេកវិទ្យានិងចំណេះដឹង និងការលើកកម្ពស់សមត្ថភាពក្នុងផ្នែកសំខាន់ៗ ដូចជា របៀបគ្រប់គ្រង

អត្ថបទនេះ សង្ខេបចំណុចសំខាន់ៗនៃការពិភាក្សានៅក្នុង សន្និសីទចក្ខុវិស័យប្រទេសកម្ពុជាឆ្នាំ២០១៧ ដែលសហការរៀបចំឡើងដោយ វិទ្យាស្ថាន CDRI និង ធនាគារ ANZ Royal នៅថ្ងៃទី២ មីនា ២០១៧។ សន្និសីទបានគូសបញ្ជាក់ពីតម្រូវការរបស់ប្រទេសកម្ពុជាដើម្បីឈានឡើងក្នុងខ្សែសង្វាក់បង្កើតតម្លៃ ផ្ដល់មតិផ្នែកគោលនយោបាយមួយចំនួន និងបង្ហាញនូវ កត្តាសំខាន់ៗនាំឲ្យមានជោគជ័យក្នុងការធ្វើទំនើបកម្មខ្សែសង្វាក់បង្កើតតម្លៃ។

**លទ្ធផលនៃ សន្និសីទចក្ខុវិស័យប្រទេសកម្ពុជា ឆ្នាំ២០១៧**
**ក្នុងកិច្ចសហការជាដៃគូរវាង វិទ្យាស្ថាន CDRI និង ធនាគារ ANZ Royal**

ក្រុមហ៊ុន និងការអនុវត្តតាមស្តង់ដាគុណភាពនានា។ ការអភិវឌ្ឍសេដ្ឋកិច្ចក្នុងបណ្តាប្រទេសកំពុងធ្វើឧស្សាហូបនីយកម្មថ្មីនៅអាស៊ីខាងកើត អាចសម្រេចបានតាមការចូលរួម និងការធ្វើទំនើបកម្មមានជោគជ័យនៅក្នុង GVCs ។

ទី២ រចនាសម្ព័ន្ធសេដ្ឋកិច្ចកម្ពុជា បានផ្លាស់ប្តូរជាខ្លាំង។ សេដ្ឋកិច្ចមានការធ្វើឧស្សាហូបនីយកម្មយ៉ាងលឿន ដោយសារជោគជ័យនៃការដាក់បញ្ចូលសហគ្រាសក្នុងស្រុកទៅក្នុង GVCs។ កម្ពុជាបានចូលរួមសកម្ម ក្នុងខ្សែសង្វាក់បង្កើតតម្លៃផ្នែកសម្លៀកបំពាក់និងស្បែកជើង និងចូលរួមកាន់តែខ្លាំងក្នុងផលិតកម្មសម្ភារអេឡិចត្រូនិក គ្រឿងផ្សំផ្សេងៗនៃរថយន្ត និងការផ្គុំដំឡើងយានយន្ត។ ក្នុងដំណាក់កាលដំបូងនៃឧស្សាហូបនីយកម្ម កម្ពុជាមានជំនាញឯកទេសក្នុងសកម្មភាពផ្សេងៗដែលប្រើពលកម្មច្រើន និងមានចំណាយទាប/តម្លៃបន្ថែមទាប។ ប៉ុន្តែឥឡូវនេះកម្ពុជាបានឡើងឋានៈជាប្រទេសមានចំណូលមធ្យមកម្រិតទាប ដូច្នេះត្រូវតែងាកទៅខាងសកម្មភាពមានតម្លៃបន្ថែមខ្ពស់វិញ ដើម្បីសម្រេចបានគោលដៅនៃឧស្សហូបនីយកម្ម។ គោលនយោបាយអភិវឌ្ឍន៍ឧស្សាហកម្មឆ្នាំ២០១៥-២៥ បានទទួលស្គាល់យ៉ាងច្បាស់ពីបញ្ហាចោទផ្នែករចនាសម្ព័ន្ធនេះ ហើយបានកំណត់ចក្ខុវិស័យដ៏ក្លាហានមួយសំដៅប្រែក្លាយ និងធ្វើទំនើបកម្មរចនាសម្ព័ន្ធឧស្សាហកម្មចេញពី ឧស្សាហកម្មប្រើពលកម្មច្រើន ទៅជា ឧស្សាហកម្មទំនើបជំរុញដោយបច្ចេកវិទ្យា និងផ្អែកលើចំណេះដឹង នៅឆ្នាំ២០២៥។ យុទ្ធសាស្ត្រអភិវឌ្ឍន៍តម្រង់ទិសទៅរក GVC នេះ កាន់តែសមស្របឡើង ព្រោះមានក្រុមហ៊ុនពហុជាតិកាន់តែច្រើនកំពុងពិចារណាធ្វើការផ្ទេរចំណែកខ្លះនៃខ្សែសង្វាក់បង្កើតតម្លៃ ទៅកាន់ប្រទេសមានសេដ្ឋកិច្ចកំពុងស្ទុះឡើង ដូចជា កម្ពុជា ជាដើម។

## ការផ្តល់មតិសំខាន់ៗផ្នែកគោលនយោបាយ

ការឈានទៅអនុវត្ត សកម្មភាពមានតម្លៃបន្ថែមកាន់តែខ្ពស់នៅក្នុង GVCs អាចសម្រេចបានឆ្លងតាម ៤ប្រភេទ៖ ផលិតផល, ដំណើរការ, ផ្នែកមុខងារ, និង អន្តរកម្មជាមួយខ្សែសង្វាក់បង្កើតតម្លៃ។ ទំនើបកម្មផលិតផល កើតមានឡើង នៅពេលដែលសហគ្រាសអាចឈានចូលទៅក្នុង ក្រុមផលិតផលកាន់តែទំនើប។ ទំនើបកម្មដំណើរការ សំដៅដល់ ការប្រែក្លាយកាន់តែមានប្រសិទ្ធភាពនូវធាតុចូល ឲ្យទៅជាធាតុចេញ តាមការប្រើបច្ចេកវិទ្យាខ្ពស់ជាង ឬការរៀបចំឡើងវិញនូវប្រព័ន្ធផលិតកម្ម។ ទំនើបកម្មមុខងារ កើតមានឡើង នៅពេលសហគ្រាសទទួលបានមុខងារថ្មីៗនៅក្នុងខ្សែសង្វាក់បង្កើតតម្លៃ ដូចជា ការចេញពីការផលិតទំនិញ ទៅធ្វើការរចនារៀបចំ(design) ឬ ការផ្សាយលក់(marketing) វិញ។ ទំនើបកម្មខ្សែសង្វាក់បង្កើតតម្លៃ សំដៅដល់ ការចូលទៅក្នុងឧស្សាហកម្មថ្មី។

យុទ្ធសាស្ត្រឈានឡើង ក្នុងខ្សែសង្វាក់បង្កើតតម្លៃ ប្រែប្រួលខុសគ្នាទៅតាមវិស័យ ហើយអាចត្រូវមានការគូបផ្សំខុសៗគ្នានូវគោលនយោបាយរដ្ឋាភិបាល យុទ្ធសាស្ត្រក្រុមហ៊ុន បច្ចេកវិទ្យា និងជំនាញផ្សេងៗ។ស្មុគស្មាញជាងនេះទៀត គឺ ទំនើបកម្មត្រូវពឹងផ្អែកលើគោលនយោបាយរបស់ប្រទេសម្ចាស់ផ្ទះផង និងលើអភិបាលកិច្ចនៃ GVCs ផង ពោលគឺ សេចក្តីសម្រេចជាយុទ្ធសាស្ត្ររបស់ក្រុមហ៊ុន ដែលរដ្ឋាភិបាលមិនអាចជះឥទ្ធិពលឲ្យប្រែប្រួលបាន។ ទោះយ៉ាងនេះក្តី នៅមានច្រកផ្នែកគោលនយោបាយខ្លះដែលអំណោយផលខ្លាំងជាងដល់ ការឈានឡើងក្នុងខ្សែសង្វាក់បង្កើតតម្លៃ។ ដោយផ្អែកលើបទពិសោធន៍ក្នុងប្រទេសមួយចំនួនដែលបានចូលរួម និងធ្វើទំនើបកម្មបានជោគជ័យនៅក្នុង GVCs អត្ថបទសង្ខេបនេះផ្តល់ជាមតិយោបល់ផ្នែកគោលនយោបាយ ដូចតទៅ៖

*១) បង្កើតបរិយាកាសអំណោយផលដល់ អាជីវកម្ម និងវិនិយោគ៖* ដោយសារ ក្រុមហ៊ុនពហុជាតិ ជាតួអង្គនាំមុខគេ នៅក្នុង GVCs ដូច្នេះជាការសំខាន់បំផុតដែលកម្ពុជាត្រូវបង្កើតបរិយាកាសអំណោយផលដល់អាជីវកម្ម ដើម្បីទាក់ទាញពួកគេ។ ទោះបីមានការកែលំអច្រើនហើយក្នុងផ្នែក ដូចជា ការគ្រប់គ្រងម៉ាក្រូសេដ្ឋកិច្ចលទ្ធភាពបានប្រើប្រាស់សេវាហិរញ្ញវត្ថុនិងព័ត៌មានវិទ្យា និងការជួយសម្រួលផ្សេងៗខាងផ្នែកពាណិជ្ជកម្ម ជាដើម ក៏បរិយាកាសវិនិយោគនៅកម្ពុជា នៅតែមិនទាន់អំណោយផលដូចនៅប្រទេសភាគច្រើនក្នុងអាស៊ាន ដោយទទួលបានចំណាត់ថ្នាក់ទាប ក្នុងការវាយតម្លៃផ្នែកអាជីវកម្ម និងសេដ្ឋកិច្ច។ ដើម្បីក្លាយជាកន្លែងជម្រើសល្អសម្រាប់ក្រុមហ៊ុនពហុជាតិនោះ ត្រូវមានជាអាទិ៍ ការបង្កើនភាពងាយស្រួលក្នុងការធ្វើអាជីវកម្ម និងការបង្កើតគ្រឿងលើកទឹកចិត្តឲ្យបានត្រឹមត្រូវ។ ដំណោះស្រាយជាអាទិភាពដល់ ភាពទន់ខ្សោយនៃបរិយាកាសវិនិយោគ រួមមាន៖

- កែលំអប្រសិទ្ធភាពស្ថាប័ន
- តម្រឹមនីតិវិធីគយ
- ពង្រឹងរបបពាណិជ្ជកម្ម និងកិច្ចសន្យា
- បង្កើនប្រសិទ្ធភាពទីផ្សារពលកម្ម ជាពិសេស វត្តមាន និងគុណភាពជំនាញ និងការសម្របសម្រួលរវាងស្ថាប័នសិក្សាអប់រំ សហគ្រាស និងរដ្ឋាភិបាល
- ពង្រឹងការជួយសម្រួលដល់អាជីវកម្ម ដើម្បីជួយទ្រទ្រង់ដល់សាខាក្រុមហ៊ុនបរទេសផង និងសហគ្រាសក្នុងស្រុកផង
- ស្វែងរក ខ្សែសង្វាក់ផ្គត់ផ្គង់និងបង្កើតតម្លៃ ដែលកម្ពុជាអាចចូលរួមបានផលច្រើន
- ទាក់ទាញ ក្រុមហ៊ុនពហុជាតិជាប់ទាក់ទិននឹង GVCs ដែលបានរកឃើញ ដើម្បីឲ្យមកធ្វើវិនិយោគនៅកម្ពុជា។

*២) កែលំអហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូន និងឡូជីស្ទិក៖* វត្តមាន និងគុណភាពនៃ ហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូន និងឡូជីស្ទិកដែលតភ្ជាប់កន្លែងជាច្រើននៅក្នុងប្រទេសកម្ពុជា ក្នុងតំបន់ និងក្នុងពិភពលោក មានសារៈសំខាន់ខ្លាំងណាស់សម្រាប់ប្រតិបត្តិការរលូនល្អនៃខ្សែសង្វាក់បង្កើតតម្លៃ។ភស្តុតាងថ្មីៗបំផុតបានពីការវិភាគឆ្លងប្រទេស បង្ហាញនូវ ទំនាក់ទំនងខ្លាំងនិងវិជ្ជមានរវាងឡូជីស្ទិកល្អ (ដែលគិតបញ្ចូលនូវ ប្រសិទ្ធភាពផ្នែកគយ គុណភាពហេដ្ឋារចនាសម្ព័ន្ធ គុណភាពសេវាឡូជីស្ទិក និងសូចនាករជាច្រើនទៀត) ជាមួយនឹងការចូលរួមក្នុង GVCs។

មតិយោបល់សំខាន់ៗបានពី សន្និសីទចក្ខុវិស័យឆ្នាំ២០១៦ លើប្រធានបទ "ជំរុញការងារទៅមុខ៖ ហេដ្ឋារចនាសម្ព័ន្ធនៅក្នុងប្រទេស និងក្នុងតំបន់ និង ឡូជីស្ទីកសម្រាប់ការតភ្ជាប់ កំណើន នឹងអភិវឌ្ឍន៍" មានជាអាទិ៍៖

- រៀបចំឲ្យស្រេចបាច់ និងដាក់អនុវត្ត ផែនការមេសម្រាប់ការដឹកជញ្ជូន និងឡូជីស្ទិក
- ជំរុញការប្រកួតប្រជែងគ្នាយ៉ាងល្អ ក្នុងវិស័យដឹកជញ្ជូន និងឡូជីស្ទិកនៅកម្ពុជា
- អភិវឌ្ឍមូលធនមនុស្ស ជាពិសេសសម្រាប់ឧស្សាហកម្មដឹកជញ្ជូន និងឡូជីស្ទិក
- ការបន្សីការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធនៅកម្ពុជា ជាមួយនឹង គំនិតផ្តួចផ្តើម "ខ្សែក្រវ៉ាត់មួយ-ផ្លូវមួយ" (BRI)។ BRI និងយន្តការរួមផ្សំនានា ដូចជា ធនាគារវិនិយោគហេដ្ឋារចនាសម្ព័ន្ធអាស៊ី (AIIB) និង មូលនិធិផ្លូវសូត្រ គឺជា ប្រភពហិរញ្ញវត្ថុថ្មីៗដែលកំពុងមានតម្រូវការជាខ្លាំង សម្រាប់ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធនៅកម្ពុជា។ហេដ្ឋារចនាសម្ព័ន្ធខ្នាតធំមួយចំនួនដូចជា តំបន់សេដ្ឋកិច្ចពិសេសនៅក្រុងព្រះសីហនុ ការកសាងផ្លូវថ្នល់ធំ(យន្តបថ) ពីក្រុងភ្នំពេញទៅក្រុងព្រះសីហនុ កំពង់ផែស្វយ័តភ្នំពេញ ផ្លូវដែកតភ្ជាប់កំពង់ផែស្វយ័តក្រុងព្រះសីហនុមកក្រុងភ្នំពេញ ជាដើម សុទ្ធសឹងជាគម្រោងធំៗ នៅក្នុង គំនិតផ្តួចផ្តើម BRI។ ក្នុងស្ថានភាពនេះ ជាការសំខាន់កម្ពុជាត្រូវកំណត់ឲ្យបានថា ក្រៅពីភាពជាដៃគូទ្វេភាគីនិងពហុភាគីដែលមានស្រាប់ តើ AIIB និងមូលនិធិផ្លូវសូត្រ អាចជួយទ្រទ្រង់យ៉ាងណាបានដល់គម្រោងធំៗផ្នែកហេដ្ឋារចនាសម្ព័ន្ធ និងការតភ្ជាប់។

*៣) តម្រឹមនីតិវិធីគយ៖* ដើម្បីឲ្យប្រតិបត្តិការជំនួញឆ្លងកាត់ព្រំដែនអាចធ្វើបានយ៉ាងរលូន ប្រកបដោយប្រសិទ្ធភាព និងអស់ចំណាយតិច ត្រូវយកចិត្តទុកដាក់កាន់តែខ្លាំងជួយទ្រទ្រង់ដល់ហេដ្ឋារចនាសម្ព័ន្ធទន់តាមការ៖

- កាត់បន្ថយ និងលុបបំបាត់នីតិវិធីច្រំដែល និងគ្មានតម្លាភាព
- ធ្វើឲ្យសាមញ្ញសំណុំឯកសារ និងនីតិវិធីផ្សេងៗ
- លុបបំបាត់ការបង់ប្រាក់ក្រៅផ្លូវការ
- ចែករំលែកព័ត៌មានគ្នា ឲ្យបានកាន់តែធំទូលាយ តាមរយៈមជ្ឈមណ្ឌលព័ត៌មានពាណិជ្ជកម្ម
- ពង្រឹង ការអនុវត្តកិច្ចព្រមព្រៀងដឹកជញ្ជូនឆ្លងកាត់ព្រំដែន (CBTA) និង យន្តការច្រកចេញចូលតែមួយ។

*៤) កសាងថែមទៀតនូវ តំបន់សេដ្ឋកិច្ចពិសេស (SEZs) និងឧទ្យានឧស្សាហកម្ម៖* បទពិសោធន៍នៅអន្តរជាតិ បង្ហាញថា SEZs មានដំណើរការល្អ សំខាន់ជាខ្លាំងសម្រាប់ ទំនើបកម្ម និងការចូលរួមក្នុង GVCs។ សកម្មភាពសំខាន់ៗសម្រាប់ការអភិវឌ្ឍ SEZ រួមមាន៖

- ការពង្រឹងសមត្ថភាពផ្នែករដ្ឋបាល និងក្របខ័ណ្ឌស្ថាប័នសម្រាប់គ្រប់គ្រងប្រតិបត្តិការ SEZs
- ការអភិវឌ្ឍតំបន់ឧស្សាហកម្មនៅតាមខេត្ត ដោយមានទាំងតំបន់កសិអាជីវកម្មផង ដើម្បីជំរុញសមត្ថភាពផលិតកម្មនៅជនបទ
- ការលើកកម្ពស់ការអភិវឌ្ឍច្រករបៀងឧស្សាហកម្ម ជាពិសេសច្រករបៀងសេដ្ឋកិច្ចតំបន់ឆ្នេរ ផ្លូវជាតិតភ្ជាប់តំបន់សេដ្ឋកិច្ចចម្បងៗ និងផ្លូវយន្តបថតភ្ជាប់ទៅប្រទេសអាស៊ាននៅជិតខាង
- ការផ្តល់សេវាជួយសម្រួលពាណិជ្ជកម្មកាន់តែប្រសើរ ការបង្កើតទំនាក់ទំនងបម្រើការងារអាចបត់បែនបាន និងការធានាឲ្យមានទាំងពលករមានជំនាញទាប និងមានជំនាញខ្ពស់។
- ការអភិវឌ្ឍឧទ្យានបច្ចេកវិទ្យា ដើម្បីទាក់ទាញក្រុមហ៊ុនពហុជាតិមានបច្ចេកវិទ្យាខ្ពស់ៗ និងផលិតកម្មរបស់ពួកគេ។

*៥) ការពង្រឹងសមត្ថភាពសហគ្រាសក្នុងស្រុក និងចំណងទាក់ទងនៃខ្សែសង្វាក់ផ្គត់ផ្គង់ក្នុងស្រុក ជាមួយនឹង GVCs៖* កង្វះសមត្ថភាពផ្គត់ផ្គង់របស់សហគ្រាសក្នុងស្រុក ជាពិសេស ទាក់ទិននឹង បច្ចេកវិទ្យាផលិតកម្ម ទម្រង់បែបបទ អភិបាលកិច្ចក្រុមហ៊ុន គុណភាពផលិតផល និងការអនុវត្តតាមបទបញ្ញត្តិផ្សេងៗ អាចរារាំងសហគ្រាសមិនឲ្យឈានឡើងបានក្នុងខ្សែសង្វាក់បង្កើតតម្លៃ។ គោលនយោបាយនានាគួរផ្តោតជាអាទិភាពលើ៖

- ការពង្រឹងសេវាជួយសម្រួលអាជីវកម្ម និងទំនើបកម្មបច្ចេកវិទ្យាផលិតកម្ម
- ការបង្កើនលទ្ធភាពទទួលបានហិរញ្ញវត្ថុ
- ការជួយឲ្យសហគ្រាសខ្នាតតូចនិងមធ្យម (SME) បានចូលរួមក្នុង GVCs
- ការកែលំអរបៀបផ្តល់ការទទួលស្គាល់ និងការកំណត់ស្តង់ដាផ្សេងៗ
- ការកសាងសមត្ថភាពសហគ្រិន ដើម្បីជួយឲ្យសហគ្រាសនានាអាចចាត់ការបានកាន់តែប្រសើរ ជាមួយនឹង ក្រុមហ៊ុនធំៗ និងវិនិយោគិនបរទេស
- ជំរុញការអភិវឌ្ឍកញ្ចុំឧស្សាហកម្ម និង SMEs ។

*៦) កសាង មូលធនមនុស្សមានគុណភាពល្អ និងមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈទំនើបៗ៖* កម្ពុជាកំពុងខិតខំកសាងធនធានមនុស្សប្រកបដោយគុណភាព និងប្រសិទ្ធភាព ដើម្បីដោះស្រាយតម្រូវការបន្ទាន់ និងក្នុងរយៈពេលវែង នៃឧស្សាហូបនីយកម្ម និងការអភិវឌ្ឍ។ បញ្ហាប្រឈមលេចធ្លោជាងគេ មានជាអាទិ៍ គុណភាពនិងកម្រិតអប់រំនៃកម្លាំងពលកម្ម, ភាពមិនស៊ីគ្នារវាងការផ្គត់ផ្គង់ នឹងតម្រូវការជំនាញ, និង កង្វះចំណេះដឹង និងជំនាញផ្នែកបច្ចេកទេស។ បើសិនគ្មានអន្តរាគមន៍ខ្លាំងក្លា ដើម្បីអភិវឌ្ឍមូលធនមនុស្សទេនោះ សេដ្ឋកិច្ចអាចងាយជាប់ក្នុងអន្ទាក់ "ជំនាញទាប-ប្រាក់កម្រៃទាប"។ ផ្ទុយទៅវិញ បើសិនកម្ពុជាអាចបន្សីគោលនយោបាយអប់រំ និងកំណែទម្រង់ស្ថាប័ន ជាមួយនឹង គោលនយោបាយឧស្សាហកម្មនោះ កម្ពុជាអាចកសាងបាននូវ កម្លាំងពលកម្មមានជំនាញគ្រប់គ្រាន់អាចប្រកួតប្រជែងគេបាន ដែលជួយឲ្យកម្ពុជាអាចឈានឡើងក្នុងខ្សែសង្វាក់បង្កើតតម្លៃ និងបន្តធ្វើឧស្សាហូបនីយកម្មឲ្យទាន់គេ។ គោលនយោបាយជាអាទិភាព មានជាអាទិ៍៖

- ការបង្កើតបរិយាកាសមួយដែលអំណោយផលដល់ ការអភិវឌ្ឍមូលធនមនុស្ស និងជំនាញ។ ក្នុងនេះគួរមាន ចក្ខុវិស័យ និងទិសដៅយ៉ាងច្បាស់ ដើម្បីកំណត់តួនាទីនៃការអប់រំនៅក្នុងសេដ្ឋកិច្ច, ការផ្សារភ្ជាប់យ៉ាងខ្លាំងក្លា ជាមួយនឹង យុទ្ធសាស្ត្រអភិវឌ្ឍន៍ឧស្សាហកម្ម, និង កិច្ចសហការពិតៗក្នុងចំណោមក្រសួងមន្ទីររដ្ឋស្ថាប័នបណ្តុះបណ្តាល និងមជ្ឈដ្ឋានឧស្សាហកម្ម។
- ការផ្លាស់ប្តូរចំណាប់អារម្មណ៍របស់សាធារណជន និងលើកស្ទួយមុខមាត់នៃការអប់រំបច្ចេកទេសនិងវិជ្ជាជីវៈ។ ដោយសារការបណ្តុះបណ្តាលវិជ្ជាជីវៈ ទទួលការចាប់អារម្មណ៍ និងឲ្យតម្លៃទាបជាង ការអប់រំតាមទម្រង់ផ្សេងៗទៀត ដូច្នេះការផ្លាស់មុខមាត់ជាថ្មី

ដល់ការអប់រំវិជ្ជាជីវៈ ត្រូវតែជាចំណែកដ៏ចាំបាច់មួយនៃកិច្ចប្រឹងប្រែងលើកស្ទួយ និងកែប្រែវិស័យនេះ។ កិច្ចការនេះត្រូវមានយុទ្ធនាការផ្សព្វផ្សាយគ្រប់បែបយ៉ាង ជួយគាំទ្រផង។

- ការកសាងចំណងទាក់ទងរឹងមាំជាមួយ វិស័យឧស្សាហកម្ម ឆ្លងតាមតម្រូវការ និងផលប្រយោជន៍ទៅវិញទៅមក ពោលគឺមានអ្នកតំណាងខាងឧស្សាហកម្ម មកចូលរួមក្នុងការអភិវឌ្ឍកម្មវិធីសិក្សា, ការផ្តល់ការបណ្តុះបណ្តាល និងវគ្គហាត់ការតាមផ្នែកឧស្សាហកម្មដ៏ជាក់លាក់, និង ការបង្កើតការស្រាវជ្រាវ និងគ្រឿងសម្រួលការផ្សេងៗរួមគ្នា។
- ការលើកកម្ពស់គុណភាព ការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ។ កិច្ចការនេះអាចសម្រេចបានតាមការទទួលយករបៀបរបបអនុវត្ត និងគំរូមានជោគជ័យនានា ដូចជា ប្រព័ន្ធបណ្តុះបណ្តាលពីរយ៉ាងរបស់អាឡឺម៉ង់ ជាដើម, ការផ្តោតខ្លាំងលើវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យា (STEM) ព្រមទាំងជំនាញទន់ផងដែរ, ការលើកកម្ពស់សមត្ថភាពគ្រូបង្រៀន, និង ការធ្វើវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធទំនើបសម្រាប់ការសិក្សាអប់រំ។
- ការធានាឲ្យ កម្មវិធីបណ្តុះបណ្តាល និងស្តង់ដានានា ស្របតាមតម្រូវការទៅអនាគតនៃ ផលិតកម្មប្រកបដោយចីរភាព នៅក្នុងឧស្សាហកម្ម ៤.0 (industry 4.0: ដំណាក់កាលទី៤ នៃឧស្សាហូបនីយកម្ម) ដែលក្នុងនោះ ការប្រើប្រព័ន្ធឌីជីតាល់បានធ្វើឲ្យខ្សែសង្វាក់បង្កើតតម្លៃ កាន់តែមានប្រសិទ្ធភាពខ្ពស់។ ការផ្លាស់ប្តូរនេះ តម្រូវឲ្យកម្ពុជាមានសមត្ថភាពខ្លាំងផ្នែក STI។

*៧) ការកសាងសមត្ថភាពផ្នែក វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ (STI)៖* ទំនើបកម្មឧស្សាកម្មមិនអាចសម្រេចបានទេ បើសិនជាគ្មានការជំរុញទំនើបកម្មផ្នែកវិទ្យាសាស្ត្រ និងសមត្ថភាពផ្នែកនវានុវត្តន៍នោះ។ ថ្វីបើកម្ពុជាចង់ ប្រែក្លាយរចនាសម្ព័ន្ធឧស្សាហកម្ម ទៅជាឧស្សាហកម្មជំរុញឡើងដោយបច្ចេកវិទ្យាក្តី ក៏សារៈសំខាន់នៃវិទ្យាសាស្ត្រនិងបច្ចេកវិទ្យា មិនទាន់បានបញ្ជ្រាបល្អទេទៅក្នុងបរិយាកាសសង្គមកម្ពុជា។ ដូច្នេះ ជាការសំខាន់បំផុតដែលកម្ពុជាត្រូវអភិវឌ្ឍគោលនយោបាយ STI ផង និងតម្រឹមវាជាមួយនឹង គោលនយោបាយអភិវឌ្ឍឧស្សាហកម្មឆ្នាំ២០១៥-២៥ ផង។ កន្លងមកមានការជឿនលឿនខ្លះហើយ តាមការបង្កើតក្រុមប្រឹក្សាជាតិផ្នែកវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា (NSTC) ក្នុងឆ្នាំ២០១៤ និងការអនុម័តចេញនូវ ផែនការមេផ្នែកវិទ្យាសាស្ត្រ និងបច្ចេកវិទ្យាឆ្នាំ ២០១៤-២០ សម្រាប់ប្រទេសកម្ពុជា។ ទោះយ៉ាងនេះក្តី សកម្មភាពជាអាទិភាពដូចខាងក្រោម គួរតែពន្លឿនបន្ថែម៖

- កសាងសមត្ថភាពក្រុមប្រឹក្សាជាតិផ្នែកវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា និងលើកកម្ពស់ចំណងទាក់ទងរឹងមាំរវាងគោលនយោបាយ STI ជាមួយនឹង គោលនយោបាយតាមវិស័យនានា ជាពិសេស ខាងអប់រំ និងឧស្សាហកម្ម។
- បង្កើតបរិយាកាសមួយពោរពេញដោយសហគ្រិនភាព និងនវានុវត្តន៍ ដែលអំណោយផលដល់គំនិតថ្មីៗ និងការបង្កើតរបស់ថ្មី តាមការលុបបំបាត់បរាជ័យនៃប្រព័ន្ធទាំងមូល និងការលើកកម្ពស់ការរៀនសូត្រពីគ្នា។
- កសាងធនធានមនុស្ស STI និងធ្វើវិនិយោគក្នុងការស្រាវជ្រាវ និងអភិវឌ្ឍន៍។
- កែលំអសមត្ថភាពស្រូបយកបច្ចេកវិទ្យារបស់សហគ្រាស និងតួអង្គផ្សេងៗទៀតនៅក្នុងប្រព័ន្ធបែបនវានុវត្តន៍ ដើម្បីបង្កើនលទ្ធភាពទាញយកអត្ថប្រយោជន៍ពីលំហូរចំណេះដឹង។

*៨) លើកស្ទួយប្រទេសកម្ពុជាក្នុងលក្ខណៈជា មជ្ឈមណ្ឌលសាកល្បងគំរូថ្មីសម្រាប់ អាស៊ាន/អាស៊ី៖*

- បង្កើតយុទ្ធនាការឃោសនាផ្សព្វផ្សាយសកម្មមួយពីកម្ពុជា ដែលជាមធ្យោបាយល្អបំផុតសម្រាប់សាកល្បងគោលគំនិតថ្មីៗ ដូចជា បទបញ្ញត្តិប៉ះពាល់តិច, សាលាកាត់ក្តីសម្រាប់ទីផ្សារមូលធនបើកចំហ, ប្រជាជននៅក្មេង, ការតភ្ជាប់នៅចំកណ្តាល អាស៊ី/អាស៊ាន។
- ទាក់ទាញវិនិយោគផ្ទាល់ពីបរទេស សម្រាប់សហគ្រាសទើបដំណើរការឡើង (start-up) ដើម្បីកសាងខ្សែសង្វាក់បង្កើតតម្លៃថ្មីៗ និងបរិយាកាសអំណោយផល។

## កត្តាសំខាន់ៗនាំឲ្យទំនើបកម្មក្នុង GVCs មានជោគជ័យ

ទំនើបកម្មប្រកបដោយជោគជ័យនៅក្នុង ខ្សែសង្វាក់បង្កើតតម្លៃ តម្រូវឲ្យមាន គោលនយោបាយរលូនគ្នាល្អ, ចក្ខុវិស័យ និងទិសដៅច្បាស់លាស់, ក្របខ័ណ្ឌច្បាប់ និងស្ថាប័នមានប្រសិទ្ធភាព, និងការសម្របសម្រួល និងសហប្រតិបត្តិការកម្រិតខ្ពស់បំផុតក្នុងចំណោមក្រសួងនានា និងរវាងរដ្ឋាភិបាល អង្គការឯកជន សមាគមឧស្សាហកម្ម ដៃគូអភិវឌ្ឍន៍ និងស្ថាប័នសិក្សាអប់រំ។ ស្ថិរភាពសេដ្ឋកិច្ច ស្ថិរភាពនយោបាយ និងសង្គម, របបពាណិជ្ជកម្មរឹងមាំ, បរិយាកាសអាជីវកម្មអំណោយផល, និងបរិយាកាសសហប្រតិបត្តិការជួយសម្រួលដល់សហគ្រាសទើបដំណើរការឡើង បច្ចេកវិទ្យា និងនវានុវត្តន៍, ទាំងអស់នេះសុទ្ធតែជាបុរេលក្ខខណ្ឌសំខាន់ៗ សម្រាប់ទំនើបកម្មគ្រប់ប្រភេទ នៅក្នុងខ្សែសង្វាក់បង្កើតតម្លៃ។ម្យ៉ាងទៀត រដ្ឋាភិបាលមានតួនាទីសំខាន់ៗបី នៅក្នុងទំនើបកម្ម GVCs គឺ ការជួយសម្រួល ការគាំទ្រផ្នែកហិរញ្ញវត្ថុ និងសកម្មភាពរៀបចំបទបញ្ញត្តិ។

**វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា (វបសអ/CDRI)**

☞ អគារលេខ ៥៦ ផ្លូវ ៣១៥ ទួលគោក ✉ ប្រអប់សំបុត្រលេខ ៦២២ ភ្នំពេញ កម្ពុជា

☎ +៨៥៥២៣ ៨៨១ ៣៨៤, ៨៨១ ៧០១, ៨៨១ ៩១៦, ៨៨៣ ៦០៣ 📠 +៨៥៥២៣ ៨៨០ ៧៣៤

email: cdri@cdri.org.kh, www.cdri.org.kh